ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់បី

ខ្សែ ១០

ក្រុងភ្នំពេញ
រោងពុម្ពរាជការ គូវែរណើម៉ង្គ
គ្រិ. ឆ្នាំ ១៩៣១
ពុ.ស. ២៤៧៣

អ្នកទទួលខុសត្រូវ ជុំ-ម៉ៅ

# បញ្ជីរឿង

ទំព័រ

១- មិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីបាលីមកជាភាសាខ្មែរ (ត) . . . . .

២- អនុមោទនវិធី អាចារ្យ សុក នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ រៀបរៀង ព្រះគ្រូសំសត្ថា ណាត តាងហ្វាងវងសាលាបរិយត្តិជាន់ខ្ពស់បានពិនិត្យផ្ទៀងផ្ទាត់ . . . . . . . . . .

"មិលិន្ទបញ្ហា និងនុអមោទនាវិធី មិនបានចុះក្នុងនេះទេ ព្រោះមានបោះសៀវភៅដោយឡែកហើយ" . . . . . . .

៣- រឿងមហាភារតយុទ្ធ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីភាសាសៀមមកជាភាសាខ្មែរ (ត) . . ៣២៧

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា

រៀបរៀង

(៣)

---

## ភាគដប់បី

### សេចក្ដីទោមនស្សរបស់ទុរយោធន៍

ទុរយោធន៍ សម្គាល់ខ្លួនថា ជាបុរសជាតិយ៉ាងទេវតាមួយអង្គដែរ គ្រានេះមកត្រូវអាវុធមិនសូវជាទម្ងន់ប៉ុន្មានទេ តែអាការដែលទ្រង់ថ្ងូរបេះនទៀត ឃើញជាការទុរន្ទុក ដូចជានឹងដាច់ជីវិតទៅចាករាងកាយ តាំងនេះមិនមែនដោយឈឺរបួសដែលត្រូវអាវុធនោះទេ ដោយឈឺចិត្តរឿងទ្រង់ក្រអើតក្រអោងប៉ោងហួសប្រមាណ យល់តែត្រូវសររបស់គេ រឿងនោះមកប៉ះពាល់ព្រះហឫទ័យ ធ្វើឲ្យព្រះហឫទ័យទ្រង់មួហ្មងជាន់ខ្ទប ដែលដើងម្នាងទៅ បរិវារមួយពួកនោះបានហែហមអមអង្គ ក្នុងខណៈដែលស្ដេចទ្រង់តទ្រោតត្រឡប់បន្ទាយ កាលចូលដល់ព្រះពន្លាទីប្រថាប់ ក៏ទម្លាក់អង្គលើកំពល ផ្ងំហាក់ដូចជាត្រៀមទ្រមនឹងធ្វើកាលកិរិយា ទ្រង់រង់មើលផ្លូវកិស្នៈដោយសេចក្ដីក្រវល់ក្រវាយ ដើម្បីនឹងបាននិយាយការដែលសំខាន់មួយយ៉ាងៗ កាលលោកមេទ័ពចាស់នោះមកដល់ ទ្រង់ក៏

ផកដង្ហើមធំហើយត្រាស់ថា កឹស្ន ខ្ញុំស្លាប់ហើយណាបង់គំនិតហើយណា យើង ពួកបាណ្ឌពយកប្រៀបយើងបានគ្រប់ផ្លូវ ។

កឹស្នៈតបសម្តីផ្អែមល្ហែមដោយក្តីស្រឡាញ់យ៉ាងបិតាថា កុំអាល កុំអាលសិន ទ្រង់កុំនិយាយយ៉ាងក្មេងដូច្នេះ របួសបន្តិចបន្តួច ប្រហែល នឹងរបួសកូនក្មេងដែលវាពើសប៉ះនេះទង្គិចនោះប៉ុណ្ណឹង យកទឹកក្តៅលាង ហើយរុំសំពត់ទៅ វាក៏សះជាទៅហើយ ។

ទុរយោធន៍តបថា ខ្ញុំឈឺចិត្តណាស់ ដែលឃើញពួកបាណ្ឌពមាន ជ័យ ។

កឹស្ននិយាយថា នឹងជាសេចក្តីឃើញយ៉ាងឆ្ងាយអំពីសេចក្តីពិត ដូចគ្នានឹងសេចក្តីឃើញខាងដើមនៃការសង្គ្រាម កាលពីបីវេលា ដែល កន្លងទៅហើយ ទ្រង់មានការក្តាំងក្តាត់ខ្លួនឯង ដោយស្មានកម្លាំងពួក បាណ្ឌពទាបពេកទៅ ក៏ឥឡូវនេះទ្រង់ក៏ក្តាំងក្តាត់យ៉ាងប្រការមិនបាន ទៀត ដូចដែលហើយមក ហើយស្មានការខូចខាតរបស់ទ្រង់ច្រើនហួស ទៅ មិនទាន់ដល់ម្ល៉ោះទេ តាមដែលពិនិត្យឃើញថា កងទ័ពយុធិស្ឋិរ មានមេទ័ពដែលមានថ្វីដៃពូកែច្រើនមែន តែតាំងអំពីនោះមកដល់ឥឡូវ នេះ គេក៏មិនទាន់មានប្រៀបអ្វីជាដុំកំភួនដួនេះហេតុផល នឹងកើតទោស ច្រើនជាងការខូចខាតមែន ។

ទុរយោធន៍ស្តេចចូលក្រឡាបន្ទំ តែព្រោះទ្រង់បានទទួលទុក្ខវេទនា

ឈើតាប់ស្នាមប្អូន ប្រកបតាំងព្រះហឫទ័យគិតអំណត់អណ្តូកយមាយ នៅតែក្នុងរឿងសឹកសង្គ្រាមផង ក្រោយប់នោះឥតបានថ្វី ប្តូលផល់បន្ទិចសោះ ក្រកាលដែលកន្ទង់ទៅសន្សំៗ ទំរាំតែគ្រប់ ៣ យាមឃើញយើងយូរអើម៉្ងះ ហាក់ដូចជាសេចក្ដីឈើតាប់ប្រហាំនៅក្នុងខ្លួនតែដូច្នេះហួតអាយុខ័យ ។

ផ្កាយព្រឹករឿងរះត្រចះឡើងក្នុងត់យប់យាមពក្រី សកុណជាតិយាសយំយាមទៀបភ្លឺ បីដូចជាទៀនអរុណឲ្យឧទ័យរឿងរះភ្លឺព្រាងស្វាងឡើង ទុះយាធទ័អានបំពត់របួសថ្មីៗ បានស្តេចនាំទ័ពចូលកាន់ស្នាមយុទ្ធ ដោយមិនឃើញផល់អាការដែលឈើតាប់ក្នុងព្រះអង្គ ។

កិស្មះទ្រង់ដំណែងជាមេទ័ព ទ្រង់តាត់ក្បួនទ័ពកុះជាព្យូហយាត្រាយាំនបែបថ្មី ដើម្បីយកជ័យជម្នះដែលខូចខាតទៅក្នុងថ្ងៃមុន តាត់ក្បួនដំរីក្រាសច្រើនស្រាប់ច្រើនជាន់ដុំញៀនរង់វ័ត សណ្ឋានដូចជាកំផែងច្រើនជាន់ រៀបជាមួយទ័ព មេកងផ្សេងៗ ទុកនៅក្រោយទ័ពដំរី យកទ័ពដំរីជាបាំងកល់រថមានទាហានជិះសេះមួយពួក ៧ នាក់ ៗ ចាំការពារក្បាល-ហានសេះកល់ទាហាន មានពលទាហានកាន់ធ្នូ បពួកៗ ចាំការពារពួកទាហានធ្នូកល់ ៗ ទាហាន មានពួកទាហានកាន់លំពែង ៧ នាក់ ៗ ជាពួកកាល់តាមក្រោយ ។

អស្ចុនក្រឡេកឃើញទ័ពមុខដូចកំផែងយាត្រាចូលមក ក៏និយាយនឹង

ក្រឹស្ណថា ទ្រង់ឃើញកងទ័ពកុរុឯណោះណា ក្រាស់ច្រើនស្រទាប់ច្រើន ជាន់ប្លុខ ថៃវទាហានរបស់គេក្រាស់ក្រែងឡើងដកបណា ក៏រឹតតែជា ការដ៏ាយទឹងក្រាយឲ្យរាលទៅដឹកានៈនោះ ទ្រង់សង្កេតឃើញប្លុខ ពួក មេទ័ពរបស់គេបន្ទំមបាំងខ្លួនក្នុងរវាងថៃវទាហានៗ ជាន់ មើលចុះមនុស្ស ជាតិអ្នកចម្បាំងខ្លាចអីម្ល៉េះ រាប្រយ័ត្នតែលោហិត ទឹងជីវិតឲ្យល់ផ្តើម របស់រាទុកប៉ុណ្ណោះ ។

លំដាប់នោះអរជុនក៏ដើរចូលទៅរកកងទ័ពមុខ ដែលកំពុងលើកចូល មក ទោណាចារ្យក៏ចេញមកទទួលមុខអរជុនបបួលឲ្យច្បាំងតតួ ព្រោះ ជាក្សត្រិយ៍ជាតិអ្នកចម្បាំង ព្រួតច្បាំងឥតមានរញ្ញកប៉ុនសសៃពេមទេ អ្នកច្បាំងទាំងពីរបានតស៊ូរគ្នាក្នុងល្បិចយុទ្ធវិធី ទាំងពីរក៏សម្តែងសេចក្តី ក្លា បញ្ញា ទឹងសេចក្តីអំណត់អត់ធន់រកអ្នកឯណាស្មើគ្មាន សង្គ្រាមគ្រា ណាក៏គ្មានស្មើដូចគ្រានោះ គ្រានោះជាឱកាសល្អបំផុត ជាឱកាសឲ្យ ឃើញទាហានឯកស៊ូគ្នា ។

ខណៈនោះកូនសរមួយទៅដោតខ្នងទោណាចារ្យ ដោយមិនដឹង ខ្លួន ទោណាចារ្យក្រឡេកមកឃើញព្រះកជាសំខដ៏ជាកជសម្ពន្ធមិត្រ របស់យុធិស្ឋិរ ក៏ឆុលឆេះដោយទោសក្តី បែរជាងទៅបាញ់ព្រះកជាសំខ ស្លាប់នៅទីងកន្លែង ។

ព្រះទៅសំខកជសុគតចំពោះមុខអរជុនដូច្នោះ ធ្វើឲ្យអរជុនឈឺចិត្ត

គិតរកផ្លូវកែកំហឹងវិញ ទើបដកដៃចេញអំពីពោណកាតាព្យដែលទ្រង់ជ្រាបថាជាកាតាព្យសម្លាប់មិនបាន ស្ទុះខ្ញាញ់ទៅរកសុសរម័នដែលទ្រង់ចាំបានថាធ្លាប់ធ្វើជាមេទ័ព លើកមកក្រោមព្រះចៅវិកដជាគ្រាដំបូងម្ដង ឯចំណេះក្នុងផ្លូវយុទ្ធវិធីរបស់សុសរម័ន នោះមិនល្មមនឹងមកទប់ទល់កម្លាំងប៉ូដែអរជុន ហេតុនោះការប្រឡូងយុទ្ធគ្រានេះ អរជុនទើបមានប្រៀបមួយពេលកាត់ផ្ដាច់ក្បាលសុសរម័ន ដោយក្រប៉ីមុតថ្លាធ្លាក់រមៀលទៅម្ខាងក្នុងលើកដំបូងដែលចូលរះអាវុធគ្នា ។

តែការមានជ័យទិនអចកជ័យអំបាលនេះ គ្រាន់តែជាភាគបន្តិចបន្តួចនៃការសង្គ្រាម ជ័យជម្នះភាគធំធ្លាក់ទៅកណ្ដាប់ដៃនៃកីស្នះ ក្នុងថ្ងៃទី ៧ គេធ្វើការយ៉ាងម៉ឺងម៉ាត់ ស៊ឹងគ្មានអ្នកណានឹងទប់ទល់បាន ពួកបាណ្ឌពបែកខ្ញាយផាយថយទៅ សូម្បីភីមនិងអរជុនដែលអ្នកពល់គ្នាជិនហើយថារឹងរិទ្ធិបំផុត ក៏ទើបមិនបានមុនរាត្រីកាលនឹងមកដល់ ទង់ជ័យកំពូលពលរបស់យុធិស្ថិរត្រូវពួកកោរពក្របែលរលំគ្រេងទៅ រាត្រីកាលក៏ងងឹតព្រាងព្រឹលចូលដល់ ត្រែសញ្ញាគាក់ច្បាំងក៏បន្លឺស្នូរសព្ទដោយរួសរាន់នារាត្រីយប់នោះ មានការកែកពយសប្បាយជ្រួលជ្រើមក្នុងបន្ទាយកុរុ ដោយឃើញកងទ័ពទុរយោធន៍មានជ័យជម្នះយ៉ាងសំខាន់ ។

លុះអរុណោទ័យបញ្ចេញរស្មីព្រឹកព្រាងស្វាងឡើង កងទ័ពទាំងសងខាងបានហែត្រាទៅកាន់យុទ្ធមណ្ឌល បានចូលប្រយុទ្ធគ្នាកាប់សម្លាប់ឈាមប្រាសស្រប់ចបពីទៀត ។

ថ្ងៃនេះជាថ្ងៃដែលភីមទិញសម្តែងកម្លាំងជាពន្លឹករបស់គេ ជ័យជម្នះបន្តិចបន្តួចរបស់ពួកកោរព កាលគ្រាដែលមានឡើងធ្វើឲ្យពួកបាណ្ឌពក្តៅក្រហាយ ជ័យជម្នះរបស់ពួកបាណ្ឌពកាលដែលកើតដូចគ្នា ធ្វើឲ្យភីស្មៈក្រោធឆេះឆួលឡើង ការដែលទឹកនៃសង្គ្រាមឡើងៗចុះៗដូច្នោះ ក៏ព្រោះមកពីភីស្មៈនិងភីមទាំងពីរប្រាណ ផ្លាស់គ្នាសម្តែងមហិទ្ធិឫទ្ធិកម្លាំងក្លាហានក្នុងកណ្តាលស្នាមយុទ្ធ ឯភីមនេះសូម្បីតែក្នុងវេលាមានអារម្មណ៍ស្ងប់ស្រួល ក៏មើលទៅសមៀមមុខគួរស្ញើងទៅហើយ កាលគេមានទោសចណ្តាលឡើងហើយ ក៏ស្ទើរដូចជាមានពលទាំងមុឺនភាំងសែនទៅក្នុងខ្លួន ថ្ងៃនេះគេក៏សម្តែងកម្លាំងមហិទ្ធិឫទ្ធិដ៏ពន្លឹកនោះទៀត បានចូលវាយកងរយ-នៃកុរុខាត់ខ្ចាយទៅអស់ទាំងកងដោយចំពោះតែម្នាក់ឯង ។

ភីស្មៈតាំងល្បួងលោមពួកទាហាន ដែលវាយរត់ទៅនោះស្ទើរបានពុំបាន ប្រឹងស្រែកអស់សំរែកថា ឱកុរុ នេះឬសេចក្តីក្លាហានដែលល្បីនាមរបស់កុរុ នេះឬប្រវេណីអ្នកចម្បាំង ដោយសេចក្តីប្រព្រឹត្តយ៉ាងនេះឬ ឈ្មោះជាទីរក្សាកេរ្តិ៍ឈ្មោះរបស់បុព្វបុរសរបស់អ្នក ចូរមើលចុះខ្លួនយើងបានយកជីវិតរបស់យើងតែម្នាក់ឯងទៅតស៊ូប្រទីនសឹក ដែលមានកម្លាំងច្រើនជាងទាំងពាន់ភាគមុឺនភាគ យើងតែម្នាក់ឯងក៏អស់កម្លាំងកាយ ពោះបើនឹងវាយតម្លៃថាកេមរបស់យើងក្លាយទៅជាទាហានកាន់អាវុធចូលតស៊ូ ក៏គង់ជាលំបាក តែម្ដងយើងក៏មិនរត់ ។

សម្ដីអម្បាលនេះ ចូលទៅក្នុងខួបហទយវត្តធាហានក្សត្រព្ភកក្សត្រិយ៍ គន្ធារី ៦ អង្គ ព្រះសម្ដីលោកមេទ័ពដូច្នោះ ឲ្យមានខមានះឡើងមក កំលាន់ រាហាថាទឹងយកជីវិតឥកាវែតឲ្យបាន ទាំង ៦ អង្គទ្រង់សេះសម្បូរដូចទឹកជោះ បររហោចដូចហ្វូងហង្សហើរឆ្លងសមុទ្រ ចូលប្រយុទ្ធរាយទ័ពបាណ្ឌពបែក ខ្ចាត់ខ្ចាយទៅ នៅសល់តែឥកាវែត (បុត្រអរជុន កើតអំពីនាងឧលុប៉ី ជំជានាគធីតា) ទទួលតស៊ូតែម្នាក់ឯង ទាល់តែសម្លាប់គន្ធារីកុមារបាន ៤ អង្គ ដោយលំដាប់ៗក គន្ធារីកុមារអង្គ ១ ណាញ្ញី នៃកុមារទាំង ៤ ដែលសុគតទៅ រូបកេងមាំងប៉ង បានតយុទ្ធនាតែតតួ មិនយូរប៉ុន្មាន ក៏ប្រហារឥកាវែតបាន ។

អរជុនបានដឹងថា ឥកាវែតត្រូវគេប្រហារស្លាប់ ក៏បណ្ដាលទោសឡើង ដូចភ្លើងព្រៃត្រូវពាយុ ឡើងជិះរេះជំលឿងស្ទុះដូចព្រះកាលបរសំដៅ ទៅរកកងទ័ពគុរុ បង្រួសរាយក្រឡប់ក្រឡិនខ្ទេចខ្ទី ដូចផែនសិលាជំធំ ធ្លាក់អំពីខ្ពស់ទៅទីទាប ធ្វើបែកក្ដីវិនាសដល់ពួកកុរុវិញខ្ទួន ។

ឃដោត្កច ជាបុត្រភីម កើតអំពីនាងហិឌិម្ពា ជារាក្សសីមានទា-ហានរួមចិត្តមួយពួកតាមទៅងររុកបុះទៅក្នុងកណ្ដាលហ្វូង ទាហានសឹក ដើម្បីសងសឹកមរណៈនៃឥកាវែត ទុរយោធន៍ជាអ្នកនាំទ័ពក្នុងចំរបញ្ជាន់ តែឃដោត្កចរាយបង្អើលក្លាំងរឹតប្រសាចទៅទាំងក្លាងទៅ ទុរយោធន៍ មិនខំតស៊ូធ្លាក់ទៅកណ្ដាលសឹកគេតែង នៃតែម្នាក់ឯង តស៊ូដោះខ្លួនបណ្ដើរ

មិនឲ្យសឹកចាប់ខ្លួនបាន ទទួលខណៈនោះមានព្រះរាជា ១ អង្គជាសម្ពន្ធមិត្របរដ៏សឹកទៅជួយ រាយកាត់រាំងទុរយោធន៍ទំនឹងសឹក គឺយដោត្តថ ឲ្យគ្រោកចេញទៅ បន្តិចកិស្នៈនាំកងទ័ពធំស្រុតទៅជួយការពារទុរយោធន៍ទៀត យដោត្តថត្រឡប់ជាធ្លាក់នៅក្នុងទីពោមព័ទ្ធវិញ ពួកបញ្ចាលមិនប្រញាប់លើកកម្លាំងទៅជួយគង់ជាចាប់ខ្លួនបាន ការច្បាំងក្នុងថ្ងៃទី ៨ នេះ ក៏នៅមិនទាន់ដាច់ខាតជាខាងណាមានជ័យ ខាងណាអចាជ័យ តាំងពីថ្ងៃដំបូងរៀងមកដល់ថ្ងៃនេះ បានប្រឹងប្រែងដណ្តើមជ័យរៀងខ្លួន តែតែសឹកទាំងសងខាងមានកម្លាំងស្មើគ្នា មិនអាចនឹងផ្តាច់ចំណែកជ័យម្ខាងៗបាន តែទុរយោធន៍ទ្រង់ជ្រាបចំនួនពាហនរបស់ព្រះអង្គ ស្លាប់បាត់បង់ទៅជាច្រើន ដែលសេសសល់នៅឃើញស្តួច ទុរយោធន៍ទ្រង់ទោមនស្សមួហ្មងព្រះហឫទ័យទៀត ដោយទ្រង់នឹកអាព្រះហឫទ័យក្នុងរឿងនឹងធ្វើការតទៅ ជាយូរបន្ទាប់ដូចម្តេចជាមិនត្រូវ ព្រះហឫទ័យរបស់ទ្រង់ត្រាំចម្បែងទៅដោយទុក្ខ ជញ្ជីងរំពឹងដល់ថ្ងៃដែលកន្លងទៅហើយ ក៏មិនឃើញផលអ្វីមួយចំណេញ ដែលនាំឲ្យញ៉ាំងចិត្តឲ្យរីករាយបាន រំពឹងទៅថ្ងៃមុខ ក៏គ្មានឃើញផ្លូវនឹងសង្ឃឹមបាន ខ្វះនេះធ្វើឲ្យទ្រង់ទ្រូងក្នុងទុក្ខ ៗ

ខណៈនោះ កណ៌ អ្នកមេបញ្ជាឧបាយ ចូលទៅគាល់ក្នុងបាក់ទីប្រថាប់របស់ទុរយោធន៍ តាំងដើមទូលញុះញង់បំផ្លើសប្រកព្រះកណ៌ទុរ-យោធន៍ ឲ្យទ្រង់សន្និះសង្ស័យថា ទូលព្រះអង្គគ្មានចេតនាបំណាំងនឹង

លប់លាងសេចក្ដីសត្យសុចរិត របស់អ្នកឯណានិមួយ ដែលព្រះករុណាទ្រង់ទុកព្រះរាជហឫទ័យ យ៉ាងស្និទ្ធឥតវង្វៀសមកយូរហើយនោះទេ តែព្រះករុណាក៏ទ្រង់ជ្រាបច្បាស់ឥតសង្ស័យថា គ្មានកន្ទំពឯណា បើទោះបីជាខ្លាំងពូកែយ៉ាងម្ដេចក៏តាមអាចញ៉ាំងសេចក្ដីសមប្រុះប្អាឲ្យសម្រេចទៅបាន បើអ្នកមេទ័ពនោះៗ មកបង្អង់ការយកចិត្តទុកដាក់ក្នុងរាជការនាទីរបស់ខ្លួន អ្នកមេទ័ពប្រៀបដូចជាក្បាលរបស់រាងកាយសេនាទាហានប្រៀបដូចជាអវយវៈឯទៀត អ្នកជាមេទ័ពគាំងសម្ដែងសេចក្ដីព្យាយាមរឹងប៉ឹងមាំមួនក្លាហាន ដោយកម្លាំងកាយនិងចិត្ត ឲ្យសចិត្តទាហានត្រូវកងក្នុងបន្ទុកបង្គាប់បញ្ជារបស់ខ្លួន ឲ្យមានចិត្តក្នុងការតស៊ូសឹកសត្រូវទូលព្រះបង្គំគិតក្រែង ..... ទូលព្រះបង្គំអាចសារភាពក្រាបទូលថាគឺស្មោះ: មានសេចក្ដីគិតស្ទាក់កំប៉ាំងក្នុងចិត្ត សេចក្ដីគ្មានសត្យសុចរិតក្នុងចិត្តរបស់មេទ័ពនោះឯងជាឈ្លួលអាវុធ ដែលអាចនឹងញ៉ាំងរាជអាណាចក្រ ឲ្យលិចលង់វិនាសបាត់ក្នុងមួយវេលាជាមិនខាន ។

ទុរយោធន៍ស្រង់ស្ដាប់ពាក្យឧបាយនេះ ព្រះហឫទ័យត្រូវប្រឹប្ប—ជិសារទៅក្នុងសេចក្ដីសង្ស័យរឹងរឹតឈឺង ដែលទ្រង់កំពុងប៉ះសន្ទិះមកហើយ ក្នុងរឿងក្ដីខ្ពកកំពូលពលរបស់ព្រះអង្គហើយ គណៈ មនុស្សសំខាន់ក្នុងរាជការទាំងបាន ក៏មកមានសេចក្ដីសន្ទិះឡើងដែរ ជាហេតុធ្វើសេចក្ដីធំធឹតក្នុងរឿងក្ដីនោះឲ្យកាំឡើងមន្តិចទៀត ប្រការ ១ ទៀត

កណ៌ាជាភ្លើងគួរសំគ្គស្លាប់ ឬ ជាភ្លើងរួមចិត្តដ៏វិតមួយរបស់ទុរយោធន៍ ហេតុដូច្នោះពាក្យទូលណែនាំរបស់គេរមែងមានទម្ងន់ គួរឲ្យជឿបាន កណ៌ា បន្ទន់និយាយមួយស្របក់ហើយក៏និយាយតទៅទៀតថា ៖

ទូលព្រះបង្គំដឹងហើយថា កិស្នៈជាមហាបិតុលារបស់ព្រះអង្គ ទំនៀមមហាបិតុលា មិនដែលធ្វើឲ្យក្មួនក្មួយរបស់ខ្លួនវិនាសហិនហោច តែព្រះករុណាគោងជ្រាបថា គេជាបុត្របុរសទាំងខាងតួ ទាំងខាងបាណ្ឌព ហើយធម្មតាមនុស្សចាស់រមែងរេន្ទ្វងលំអៀង សម្ដែងសេចក្ដីស្រឡាញ់អឺ តើដល់ម្ខាងច្រើនជាងម្ខាង ត្បិតមនុស្សគ្រប់រូប រមែងមានក្មួនក្មួយ ជាទីស្រឡាញ់ពេញចិត្ត និងកល្យាណនារីជាទីស្នេហារបស់គេ កិស្នទឹង បានផុតអំណាចកិលេសអម្បាលម៉ាណនេះហើយក៏ទេ ដែលគេសម្ដែងសេចក្ដីលំអៀងទៅខាងបាណ្ឌពនោះ ដ៏ងបានតាលគ្រាប្រឹក្សាស្ងប់សឹកគេទូលធ្ងារស្ត្រីឲ្យកើតសន្តិភាពប្រគល់ឲ្យបាណ្ឌពវិញ តែខនេះមិនបាច់ព្រួយការ ទូលព្រះបង្គំនឹងរំលែកមកសម្ដែងឲ្យពិស្ដារ ៕

អរគុណអ្នក កណ៌ា យើងអរគុណអ្នកហើយ ទុរយោធន៍តបដូចមនុស្សមមើយល់សប្ដ រួចក៏ស្ដេចត្រាស់ប្រាប់ទៅឯធុះក៏ទំភាគកិស្នៈស្រែកសួរថា ខ្ញុំបួលទៅបានឬទេ ៕

អ្នកណាម្នាំង មកទាំងយប់ទាំងភ្ញាក្រខុសពេលវេលាដូច្នេះ សំឡេងកិស្នស្រែកសួរទៅវិញ ៕

ខ្ញុំទុរយោធន៍ ។

សុំអភ័យទោស អញ្ជើញស្ដេចចូលមកខាងក្នុង អ្វីក៏ដេញឲ្យទ្រង់ក្រោកចេញអំពីទីបន្ទំតាំងយប់តាំងអធ្រាត្រ ។

ខ្ញុំមានសេចក្ដីភ្ជួបចិត្ត ដែលមកកំពោកសាពេកទ្រង់ក្នុងវេលាចូលដំណេក សេចក្ដីគិតមួយខ្ទង់ដ៏ធ្ងន់មកសង្កត់ហាក់យកខ្ញុំ មកនេះដើម្បីរំសាយឲ្យស្រាលទ្រូង ។

សេចក្ដីគិតផ្ដេសផ្ដាសចាស់ៗ របស់ទ្រង់ទេដឹង ។

ទេ មិនមែនសេចក្ដីគិតផ្ដេសផ្ដាស ខ្មោចអ្វីក៏ចូល ពីព្រលប់ដល់ផ្ទារនេះខ្ញុំដេកមិនលក់ សេចក្ដីខ្មោចៗ នេះឯងក៏ចូលគ្របសង្កត់ធ្វើទុក្ខខ្ញុំ ។

(នៅមានត)